# សេចក្តីថ្លែងការណ៍រួម

សេចក្តីថ្លែងការណ៍រួមនេះធ្វើឡើងរវាង ខេប៊ី ប្រាសាក់ និងអ្នកតវ៉ាពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់ IFC ជាមួយនឹង ខេប៊ី ប្រាសាក់ តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុរបស់ពួកគេជាមួយ MEF (លេខគម្រោង IFC #២៧៨២៧)។ ការតវ៉ានេះត្រូវបានសម្គាល់លេខ "Cambodia MEF ០៩"។

ក្នុងដំណើរការវាយតម្លៃរបស់ក្រុមការងារ CAO នេះ អ្នកតវ៉ា និងអតិថិជនប្រយោលរបស់ IFC ខេប៊ី ប្រាសាក់ បានបង្ហាញចំណាប់អារម្មណ៍ចូលរួមជាមួយនឹងដំណើរការដោះស្រាយវិវាទ ដោយក្រុមការងារ CAO ជាអ្នកសម្របសម្រួល ក្នុងការដោះស្រាយវិវាទលើកឡើងក្នុងវិវាទតវ៉ាពាក់ព័ន្ធនឹង ខេប៊ី ប្រាសាក់ ដោយប្រើប្រាស់វិធីសាស្ត្រចចារសហការ។ ភាគីទាំងអស់បានឯកភាពគ្នាលើវិធានប្រជុំដែលជាមគ្គុទេសក៍ក្នុងការសម្របសម្រួលកិច្ចសន្ទនា នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៥។

លទ្ធផលដែលទទួលបានពីដំណើរការស្ម័គ្រចិត្តដោះស្រាយវិវាទនេះ គឺភាគីទាំងអស់សម្រេចព្រមព្រៀងគ្នា និងបានចុះហត្ថលេខាបញ្ចប់វិវាទទាំងស្រុង នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២៥ និងបានឯកភាពគ្នាឱ្យក្រុមការងារ CAO បន្តតាមដានការអនុវត្តកិច្ចព្រមព្រៀងបញ្ចប់វិវាទនេះ រហូតដល់ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២៥ និងអាចពន្យារពេលវេលាតាមដានបន្ថែម។